**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥០៨ សហវ.ឧហ

# ប្រកាស
## ស្ដីពី
## ការដកហូតអាជ្ញាប័ណ្ណឆ្នោតជាបណ្ដោះអាសន្នរបស់ ក្រុមហ៊ុនឆ្នោត ជាអ៊ីន អន្តរជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១.១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០១ នស/រកម ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស/ ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង មានការកែប្រែក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសអោយប្រើដោយ ព្រះរាជក្រម លេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ ០១ ន.ស.រកម ០.១៩៤/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញលិខិតលេខ ១០១០ សជណ.ផស ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៩៦ របស់ទីស្ដីការគណៈរដ្ឋមន្ត្រីស្ដីពីការសុំបង្កើតឆ្នោតឯកជនរបស់ក្រុមហ៊ុនឆ្នោត អន្តរជាតិ ៩៩
- បានឃើញសារាចរណែនាំលេខ ០១០ សហវ.សរ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០០ ស្ដីពីកំណែទំរង់ប្រព័ន្ធគ្រប់គ្រងអាជីវកម្មឆ្នោត-ឡូតូ
- បានឃើញអាជ្ញាប័ណ្ណឆ្នោតលេខ ០០៣ សហវ. ឧហ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០១ ផ្ដល់ ជូនអ្នកស្រីនាយិកាក្រុមហ៊ុនឆ្នោត ជាអ៊ីន អន្តរជាតិ
- បានឃើញលិខិតលេខ ០០២ សហវ.ឧហ ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការធ្វើអាជីវកម្មឆ្នោតរបស់ក្រុមហ៊ុនឆ្នោត ជាអ៊ីន អន្តរជាតិ
- បានឃើញលិខិតលេខ ១០៩ សហវ ឧហ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្ដីពីការផ្ដល់តារាងតុល្យភាព ឆ្នាំ ២០០២
- បានឃើញតំរូវការចាំបាច់របស់ក្រសួង ក្នុងការគ្រប់គ្រងអាជីវកម្មឆ្នោត-ឡូតូ ឱ្យមានសណ្ដាប់ធ្នាប់

## សំរេច

**ប្រការ ១ :** ដកហូតជាបណ្ដោះអាសន្ននូវអាជ្ញាប័ណ្ណឆ្នោតលេខ ០០៣ សហវ.ឧហ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០០១ របស់ក្រុមហ៊ុនឆ្នោត ជាអ៊ីន អន្តរជាតិ ដោយមូលហេតុក្រុមហ៊ុនពុំបានអនុវត្តតាមលក្ខខ័ណ្ឌនៃសេចក្ដីណែនាំអនុវត្តអាជ្ញាប័ណ្ណឆ្នោត ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០១ លិខិតជូនដំណឹងលេខ ០០២ សហវ.ឧហ ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៣ ស្ដីពីដំណើរការអាជីវកម្មឆ្នោត-ឡូតូ និង លិខិតលេខ ១០៩ សហវ.ឧហ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៣ ស្ដីពីការផ្ដល់តារាងតុល្យភាពឆ្នាំ ២០០២ ។

**ប្រការ ២ :** ការបន្តសុពលភាពអាជ្ញាប័ណ្ណជាថ្មី គឺជាសិទ្ធរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៣ :** អគ្គលេខាធិការ នាយកខុទ្ទកាល័យ លោកប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ លោកប្រធាននាយកដ្ឋានពន្ធដារ លោកប្រធានរតនាគារជាតិ លោកប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសាម៉ីក្រុមហ៊ុន ត្រូវទទួលអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ ៤ :** ប្រកាសនេះមានសុពលភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០៣

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**គាត ឈន់**

**ចម្លងជូន**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

"ដើម្បីជូនជ្រាប"

- ដូចប្រការ៣

"ដើម្បីអនុវត្ត"

- ឯកសារ-កាលប្បវត្តិ